**ONLINE LIBRARY**
(www.onekhmer.org/onlinelibrary)

| | |
|---|---|
| **Title:** | Social and Environmental Safeguards: Lessons from Cambodia REDD+ Pilot Projects (Khmer) |
| **Name of Author** | Nguon Pheakkdey, Chhun Delux |
| **Name of University** | Clark University |
| **Country of Study** | United States |
| **Major** | Human-Environment Geography |
| **Degree** | PhD |
| **Course Title** | |
| **Type of Document** | Policy Brief for Cambodia Development Review, Vol 20, Issue 2 |
| **Year** | 2016 |

# ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន៖ បទពិសោធន៍ទទួលបានពីគម្រោងសាកល្បងនៃកម្មវិធីរេដ+

## សេចក្ដីផ្ដើម

អនុសញ្ញាក្របខ័ណ្ឌនៃ អង្គការសហប្រជាជាតិស្ដីពី ការប្រែប្រួលធាតុអាកាស (UNFCCC 2013) បានចែងថា រេដ+ (REDD+) សំដៅដល់គោលនយោបាយ និងវិធានការទាំងឡាយ ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន ពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ និងលើកកម្ពស់តួនាទីធ្វើការអភិរក្សគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងបង្កើនស្តុកកាបូននៃព្រៃឈើ នៅតាមប្រទេសកំពុងអភិវឌ្ឍន៍ (រេដ+)។ តាំងពីការបំផុសគំនិតផ្ដួចផ្ដើមក្នុងឆ្នាំ២០១០ មក ប្រធានបទដែលមានការស្រាវជ្រាវច្រើនជាងគេមួយលើ រេដ+ គឺផលប៉ះពាល់ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍ និងអនុវត្ត រេដ+ សម្រាប់បរិស្ថាន និងសង្គម (Angelsewn 2010; Nguon and Kulakowski 2013; Peskett and Todd 2013)។ ហានិភ័យ និងអត្ថប្រយោជន៍អាចកើតមានឡើងនេះ គេបានលើកមកពិភាក្សា ក្នុងបំណងផ្ដល់នូវប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន ឲ្យបានគ្រប់គ្រាន់។ កម្មវិធី UN-REDD របស់អង្គការសហប្រជាជាតិ (2015) បានឲ្យនិយមន័យប្រព័ន្ធធានាសុវត្ថិភាពថាជា បណ្ដាដំណើរការ ឬគោលនយោបាយកំណត់ឡើងដើម្បី បញ្ចៀស ឬកាត់បន្ថយហានិភ័យអាចកើតមានផលប៉ះពាល់អវិជ្ជមានលើសង្គម និងបរិស្ថាន និងដើម្បីធានាឲ្យការអនុវត្ត រេដ+ ផ្ដល់នូវអត្ថប្រយោជន៍សម្រាប់សង្គម និងបរិស្ថាន។

ប្រព័ន្ធធានាសុវត្ថិភាព អាចចែកចេញជាពីរក្រុម។ ក្រុមទី១ រួមមាន ឯកសារស្ដីពីការសម្រេចចិត្តផ្សេងៗ ដែល UNFCCC បានអនុម័តឡើង និងមានជាអាទិ៍ កិច្ចព្រមព្រៀង Cancun Agreements, សេចក្ដីណែនាំ Durban Guidance, ក្របខ័ណ្ឌ Warsaw Framework សម្រាប់ រេដ+ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាពេលថ្មីៗនេះ។ ក្រុមទី២ រួមមាន ការតម្រូវផ្សេងៗដែលបានកំណត់ឡើងនៅក្រៅដំណើរការ UNFCCC ដោយអ្នកគាំទ្រទីផ្សារកាបូនស្ម័គ្រចិត្ត ដូចជា Verified Carbon Standard (VCS) និង Climate, Community and Biodiversity Standard (CCBS) (Nguon and Chhun 2015) ជាដើម។

ក្រោយកិច្ចប្រជុំ UNFCCC ឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុវត្តគម្រោងសាកល្បង រេដ+ ដោយមានការអនុម័តយល់ព្រមលើ សហគមន៍ព្រៃឈើឧត្ដរមានជ័យ ក្នុងឆ្នាំ២០០៨ និង ព្រៃការពារសីមា ក្នុងខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០០៩។ គម្រោងទាំងពីរមានដាក់អនុវត្តនូវ សំណុំខ្លះនៃប្រព័ន្ធធានាសុវត្ថិភាព សង្គម និងបរិស្ថាន សំដៅបំពេញតាមការតម្រូវផ្សេងៗនៅក្នុង VCS និង CCBS។ ដូច្នេះ អត្ថបទនេះមានគោលដៅមិនមែនធ្វើការវាយតម្លៃលើការដាក់អនុវត្ត ប្រព័ន្ធធានាសុវត្ថិភាពរបស់ UNFCCC នៅកម្ពុជា នោះទេ ប៉ុន្តែដើម្បីពិនិត្យ និងប្រៀបធៀបបទពិសោធន៍នៃគម្រោងទាំងពីរ ក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ VCS និង CCBS។ ដើម្បីបំភ្លឺបន្ថែមពីបែបបទដែលវិធានការទាំងនេះ ជួយកាត់បន្ថយហានិភ័យផ្សេងៗ ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រ បង្កើតឡើងដោយ Roe et al. (2013) ដែលបានបែងចែកប្រព័ន្ធធានាសុវត្ថិភាព រេដ+ ជាបីប្រភេទគឺ សង្គម បរិស្ថាន និងនីតិវិធីផ្លូវការ។

## វិធីសាស្ត្រ

ការសិក្សានេះ ប្រើប្រាស់ការវិភាគប្រៀបធៀបបែបគុណភាព។ ព័ត៌មានបានប្រមូលយកតាមការធ្វើសម្ភាសន៍ជាមួយ អ្នកផ្ដល់ព័ត៌មានគន្លឹះ ការពិភាក្សាតាមក្រុមស្នូល និងការសិក្សាស្រាវជ្រាវលើឯកសារមានស្រាប់ ដូចជា របាយការណ៍រដ្ឋាភិបាល សារព័ត៌មាន អត្ថបទសង្ខេបគោលនយោបាយ និងការសិក្សាពីភាពអាចធ្វើបាន ជាដើម។ ទិន្នន័យជាក់ស្ដែងស្ដីពីគម្រោងសាកល្បងទាំងពីរ បានប្រមូលយកតាមការចុះសិក្សាដល់កន្លែង ចំនួន ២លើកគឺ ពីខែតុលា ដល់ ធ្នូ ២០១៣ និង ពីខែមករា ដល់ កក្កដា ២០១៥។ ការចុះសិក្សាដល់កន្លែងទាំងនេះ ទទួលបានជំនួយជាអំណោយពី បណ្ដាញស្រាវជ្រាវមេគង្គប្រកបដោយចីរភាព (SUMERNET) ជំហានទី៣ របស់វិទ្យាស្ថាន Stockholm Environment Institute។

សរុបទាំងអស់មក ក្រុមស្រាវជ្រាវបានធ្វើ ៥០សម្ភាសន៍ពាក់កណ្ដាលរៀបរយ ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះដែលតំណាងឲ្យ ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ការពិភាក្សាតាមក្រុមស្នូល បានអនុវត្តឡើងជាមួយ អ្នកតំណាងមកពី ១៣សហគមន៍ព្រៃឈើ ក្នុងខេត្តឧត្ដរមានជ័យ និង ២០សហគមន៍ជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី។ ក្នុងការវិភាគទិន្នន័យ ក្រុមស្រាវជ្រាវបានប្រើកម្មវិធីកុំព្យូទ័រសម្រាប់វិភាគទិន្នន័យ NVivo ១០ ជាឧបករណ៍ជំនួយ ហើយបានប្រើគួបផ្សំគ្នានូវ មុខងារជាច្រើននៃកម្មវិធីកុំព្យូទ័រនេះ ដើម្បីដាក់លេខកូដជាទូទៅ និងធ្វើការស្រាវជ្រាវជាក់លាក់មួយចំនួនលើទិន្នន័យមានដាក់លេខកូដរួចហើយ ដែលក្រុមស្រាវជ្រាវ

---

អត្ថបទនេះ ចងក្រងឡើងដោយបណ្ឌិត ងួន ភក្តី អ្នកសម្របសម្រួលផ្នែកស្រាវជ្រាវដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង លោក ឈុន ឌីលុច ប្រធានការិយាល័យឥណទានកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុនៃរដ្ឋបាលព្រៃឈើ។ សូមយោងអត្ថបទនេះថា៖ Nguon Pheakkdey and Chhun Delux. 2016. “Social and Environmental Safeguards: Lessons from Cambodia REDD+ Pilot Projects.” *Cambodia Development Review* 20(2): 10-14.

បានរៀបចំផ្តុំវាក្រោម ៣ប្រធានបទគឺ សង្គម បរិស្ថាន និងនីតិវិធីផ្លូវការ (Roe et al. 2013)។

## និយមន័យពាក្យគន្លឹះ

វាក្យស័ព្ទខ្លះ ដែលយកមកប្រើនៅក្នុងឯកសារនេះ មានន័យជាក់លាក់សម្រាប់បញ្ហា រេដ+[1]។ UNFCCC (2014) បានកំណត់និយមន័យពាក្យទាំងនោះដូចតទៅ៖

- **ការបង្កបន្លាស់ទី (displacement)**៖ កត្តាជំរុញការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ត្រូវបានផ្លាស់ទីចេញពីតំបន់មានគម្រោង រេដ+ ទៅកាន់តំបន់ដទៃទៀតដែលគ្មានគម្រោងនេះ។
- **ការជ្រាបចេញ**៖ កំណើនណាមួយនៃ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ទៅក្រៅតំបន់មានគម្រោង រេដ+ ដែលជាលទ្ធផលនៃសកម្មភាពគម្រោង។
- **ភាពអចិន្ត្រៃយ៍**៖ កាបូន ត្រូវបានស្តុកទុកជាបណ្តោះអាសន្នប៉ុណ្ណោះ ហើយក្រោយមកនឹងត្រូវបញ្ចេញទៅវិញទៀត ទៅក្នុងបរិយាកាស។
- **ការប្រែប្រួលបញ្ច្រាស (reversal)**៖ កង្វះការធានាគួរឲ្យជឿជាក់ថា សកម្មភាពប្រើប្រាស់ដីពីដើមទី នឹងមិនវិលទៅរកសភាពដើមវិញទេ ក្រោយពេលគម្រោងចប់អស់។

## ប្រព័ន្ធធានាសុវត្ថិភាពសហគមន៍ព្រៃឈើឧត្តរមានជ័យ

គម្រោងសាកល្បង រេដ+ នៅសហគមន៍ព្រៃឈើឧត្តរមានជ័យ ស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា។ គម្រោងនេះ គ្របដណ្តប់លើ ១៣សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប ៦៤.៣១៨ហិកតា និង ៥៨ភូមិ ហើយមានប្រជាជនទាំងអស់ប្រមាណ ១០.០០០គ្រួសារ។ តាំងពីឆ្នាំ២០០៩ មក អង្គការផេកកម្ពុជា (Pact Cambodia) បានបម្រើការជាដៃគូអនុវត្តគម្រោង ដោយរួមសហការជាមួយ រដ្ឋបាលព្រៃឈើ ក្រុមសហគមន៍ព្រៃឈើ ទាំង ១៣ក្រុមហ៊ុន Terra Global Capital សមាគមអភិវឌ្ឍន៍កុមារ សហគមន៍ព្រៃឈើសង្ឃរុក្ខវ័ន្ត និងអាជ្ញាធរមូលដ្ឋាន (Nguon 2014)។

គម្រោងនេះ បានធានានូវសិទ្ធិកាន់កាប់ដីធ្លីសម្រាប់សហគមន៍ព្រៃឈើ ១៣កន្លែង ដោយមានកិច្ចព្រមព្រៀងរយៈពេល ១៥ឆ្នាំ រវាងរដ្ឋបាលព្រៃឈើ នឹងក្រុមសហគមន៍ព្រៃឈើ។ កិច្ចការនេះត្រូវមានកិច្ចប្រឹងប្រែងខ្លាំងក្លា ធ្វើការប្រមូលផ្តុំអ្នកពាក់ព័ន្ធនានា ផ្តល់ការបណ្តុះបណ្តាល និងជួយបង្រៀនសហគមន៍ ឆ្លងតាមដំណើរការ និងការតម្រូវផ្សេងៗ ដើម្បីផ្តល់ភាពស្របច្បាប់ដល់សហគមន៍ព្រៃឈើ។ ស្របតាមកិច្ចព្រមព្រៀងស្តីពីសហគមន៍ព្រៃឈើ គឺមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការប្រើប្រាស់សម្រាប់ការចិញ្ចឹមជីវិតនូវ ផល និងអនុផលព្រៃឈើ (NTFP)។ មានការអនុញ្ញាតផងដែរឲ្យអ្នកភូមិ បន្តប្រើប្រាស់ដីកសិកម្មដែលមានស្រាប់ នៅក្នុងព្រំប្រទល់នៃសហគមន៍ព្រៃឈើ ប៉ុន្តែមិនអនុញ្ញាតឲ្យពង្រីកដីទាំងនោះទេ។

កន្លងមកមានការប្រជុំពិគ្រោះយោបល់ជាច្រើន ដើម្បីធានាថា ម្ចាស់ដីទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយពេញចិត្តចូលរួមក្នុងគម្រោងនេះ។ អ្នកគាំទ្រគម្រោងបានរចនារៀបចំដំណើរការពិគ្រោះយោបល់របស់ខ្លួន ដោយផ្អែកលើគោលការណ៍ មានការយល់ព្រមជាមុន មានព័ត៌មានគ្រប់គ្រាន់ និងសេរីភាពក្នុងការចូលរួម (FPIC)។ ឧទាហរណ៍ គម្រោងនេះបានរៀបចំសិក្ខាសាលាជាច្រើននៅក្នុងប្រមាណ ៥០ភូមិ និងនៅកម្រិតស្រុក និងខេត្ត ដើម្បីពង្រីកការយល់ដឹងរបស់សហគមន៍ អំពី រេដ+ និងសកម្មភាពគម្រោង ព្រមទាំងផ្តល់ឲ្យពួកគេនូវឱកាស និងពេលវេលាគ្រប់គ្រាន់ ដើម្បីសម្រេចចិត្តចូលរួម ឬមិនចូលរួមក្នុងគម្រោង។ ជាលទ្ធផល ទាំង ១៣ក្រុមសហគមន៍ព្រៃឈើ បានយល់ព្រមដោយផ្ទាល់មាត់ចូលរួមក្នុងគម្រោង។

ទិដ្ឋភាពគួរឲ្យកត់សំគាល់មួយនៃ ដំណើរការពិគ្រោះយោបល់ គឺអ្នកគាំទ្រគម្រោង បានផ្តល់ព័ត៌មានទៅសហគមន៍នានាថា សហគមន៍នឹងទទួលបានការផ្តល់ប្រាក់ជាច្រើនពីគម្រោង។ កត្តានេះ អាចជាហេតុផលចម្បងមួយនៃការសម្រេចចិត្តចូលរួមរបស់សហគមន៍។ ការប្រាប់សហគមន៍ពីការផ្តល់ប្រាក់ពីគម្រោង រេដ+ បានបង្កើនការរំពឹងទុកពីការទទួលបានអត្ថប្រយោជន៍ជាប្រាក់កាស។ ប៉ុន្តែការយឺតយ៉ាវក្នុងការទទួលបានការផ្តល់ប្រាក់ពីគម្រោង រេដ+ បានបង្កើតជាបញ្ហាប្រឈមក្នុងការធានាឲ្យមានការបន្តគាំទ្រ និងចូលរួមក្នុងសកម្មភាពគម្រោងពីសំណាក់ សមាជិកសហគមន៍ព្រៃឈើ។

គម្រោងនេះដាក់អនុវត្តវិធានការជាច្រើន ដើម្បីធានាសុវត្ថិភាព និងឃ្លាំមើលជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ព្រៃស្រោង និងព្រៃល្បោះស្ងួត ដោយយកចិត្តទុកដាក់ជាពិសេសទៅលើ តំបន់អភិរក្សមានតម្លៃខ្ពស់ ដែលសំខាន់សម្រាប់ពូជសត្វព្រៃកម្រៗ។ យុទ្ធសាស្ត្រនេះ ត្រូវមានការបំផុសការយល់ដឹងឲ្យបានកាន់តែច្រើន ក្នុងចំណោមសហគមន៍មូលដ្ឋានអំពី តម្លៃនៃជីវៈចម្រុះ ក៏ដូចជា ការលើកកម្ពស់ការដើរល្បាត និងជំនាញស្តារជម្រកសត្វឡើងវិញ ដើម្បីការពារព្រៃឈើទល់នឹងការកាប់ឈើ ការបរបាញ់ខុសច្បាប់ និងភ្លើងឆេះព្រៃ ព្រមទាំងទប់ស្កាត់ការរេចរឹលជម្រកសត្វព្រៃសំខាន់ៗ។ ទោះយ៉ាងណាក្តី គម្រោងនេះ មិនមានវិធានការច្បាស់លាស់ សម្រាប់គ្រប់គ្រងហានិភ័យនៃការប្រែប្រួលបញ្ច្រាស និងការបង្កបន្លាស់ទីនោះឡើយ។ ជាលទ្ធផល គម្រោងនេះកំពុងប្រឈមនឹង ហានិភ័យនៃការប្រែប្រួលបញ្ច្រាសវិញ ដោយសហគមន៍ខ្លះកំពុងរងការសម្លុតគំរាម ពីសំណាក់អ្នកកាប់ឈើប្រដាប់ដោយអាវុធ។ ម្យ៉ាងវិញទៀត ក៏មិនទាន់មានការកំណត់ច្បាស់ដែរថា អ្នកណាទទួលខុសត្រូវលើការការពារព្រៃឈើក្នុងតំបន់ទ្រនាប់នៅព័ទ្ធជុំវិញព្រៃសហគមន៍។

ទោះបីជាគម្រោងនេះ មានអ្នកពាក់ព័ន្ធជាច្រើនក្រុមចូលរួមក្តី ប៉ុន្តែនៅមានការងារត្រូវធ្វើថែមទៀត ដើម្បីជំរុញសមធម៌យេនឌ័រ និងពង្រឹងការចូលរួមរបស់ស្ត្រី។ តំណាងសហគមន៍ភាគច្រើនលើសលុបជាបុរស ព្រោះក្នុងចំណោមតំណាងសហគមន៍ព្រៃឈើទាំង១៣ មានតែមួយរូបប៉ុណ្ណោះ ជាស្ត្រី។ តួលេខនេះ បង្ហាញពីតម្រូវការពិនិត្យអង្កេតថែមទៀត ដើម្បី

1 សម្រាប់បញ្ជីពេញលេញនៃវាក្យស័ព្ទ REDD+ សូមរកមើលនៅក្នុង UNFCCC 2014។

ស្រាវជ្រាវរកមើលថា តើសមភាពយេនឌ័រមានការទទួលយក និងគោរពតាមប៉ុណ្ណា ក្នុងពេលធ្វើការសម្រេចចិត្តលើចំណុចសំខាន់ៗនៃគម្រោង។

តំណាងសហគមន៍ព្រៃឈើ បានរាយការណ៍ថា ការតវ៉ា និងការមិនពេញចិត្តផ្សេងៗ តែងបានដាក់ជូនទៅដល់អ្នកទ្រទ្រង់គម្រោង។ ប៉ុន្តែក្នុងពេលកន្លងមក អ្នកតវ៉ាមិនទាន់ពេញចិត្តទេនឹងសមត្ថភាពមានកម្រិតរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាដែលប្រជាជនមូលដ្ឋានត្រូវប្រឈមមុខ។ តំណាងសហគមន៍ព្រៃឈើបានប្រាប់ទៀតថា ដោយសារកង្វះខាតចំណេះដឹង និងថវិកា ពួកគេក៏មិនអាចស្វែងរកជំនួយទ្រទ្រង់ពីភាគីទី៣ ដើម្បីជួយបញ្ជាក់ពីការមិនពេញចិត្តរបស់ខ្លួន។ លទ្ធផលរកឃើញនេះ បានគូសបញ្ជាក់ពីតម្រូវការពិនិត្យអង្កេតបន្ថែមលើបញ្ហានេះ។

## ប្រព័ន្ធធានាសុវត្ថិភាពតំបន់ព្រៃការពារសីមា

គម្រោងសាកល្បង រេដ+ ព្រៃការពារសីមា សំដៅបំផុសជំនួយគាំទ្រពីសាធារណជន និងការចូលរួមក្នុងកិច្ចការពារព្រៃឈើមានវ័យចំណាស់ដែលមានសារៈសំខាន់ សម្រាប់ប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់ស្នូលមួយទំហំ ១៨០.៥១៥ហិកតា ក្នុងខេត្តមណ្ឌលគិរី នៅភាគខាងកើតនៃប្រទេសកម្ពុជា។ តំបន់នេះល្បីល្បាញថា សម្បូរពូជសត្វព្រៃ ដែលមានសារៈសំខាន់សម្រាប់ពិភពលោក។ ឯកសារគម្រោង (FA and WCS 2011) បញ្ជាក់ថា នៅក្នុងតំបន់គម្រោងមាន ២០ភូមិ ដែលជាលំនៅរបស់ជនជាតិដើមភាគតិចព្នងប្រមាណ ១០.០០០នាក់។ នៅខែឧសភា ២០១៦ គម្រោង រេដ+ សីមា បានឆ្លងផុតដំណាក់កាលបញ្ជាក់ភាពអាចទទួលយកបាន យោងតាមលក្ខខណ្ឌតម្រូវរបស់ VCS និង CCBA ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលផ្ទៀងផ្ទាត់មើល (CCBS 2016)។ ដើម្បីអាចលក់ឥណទានកាបូន គម្រោង រេដ+ ដោយស្ម័គ្រចិត្ត ត្រូវឆ្លងឲ្យផុតទាំង ដំណាក់កាលបញ្ជាក់ភាពអាចទទួលយកបាន និងការផ្ទៀងផ្ទាត់មើល។ ថ្វីបើរយៈពេលទទួលបានឥណទាន នឹងបន្តទៅមុខរហូតដល់ ៦០ឆ្នាំ ប៉ុន្តែគេប៉ាន់ស្មានថា គម្រោងនេះអាចជួយកាត់បន្ថយបន្សាយឧស្ម័នកាបូនិកដល់ប្រមាណ ៥៨លានតោនក្នុងរយៈពេល ១០ឆ្នាំដំបូងរបស់វា (FA and WCS 2011)។

ឯកសារគម្រោងមានចែងច្បាស់ថា សហគមន៍មានសិទ្ធិប្រើប្រាស់និងអាស្រ័យផល (usufructory rights) លើផលិតផលឈើ និងអនុផលព្រៃឈើ និងអាចបន្តធ្វើកសិកម្មចិញ្ចឹមជីវិតនៅលើដីដែលខ្លួនបានកាន់កាប់ដោយស្របច្បាប់។ គម្រោងក៏បានធានានូវសិទ្ធិកាន់កាប់លើ ដីកសិកម្ម ដីទំនេរ និង ដីលំនៅដ្ឋានរបស់ពួកគេដែរ។ ដំណើរការនេះរួមមាន ការគូរផែនទីដីសហគមន៍ជាមួយសហគមន៍ និងការបង្កើតឯកសារច្បាប់សម្រាប់ស្នើសុំកម្មសិទ្ធិដីសហគមន៍ពីរដ្ឋាភិបាល។ ដូច្នេះមិនត្រូវមានការបង្ខំឲ្យអ្នកកាន់កាប់ដីលំនៅដ្ឋាន ឬដីស្រែចំការ ដោយស្របច្បាប់ ផ្លាស់ទីទៅកន្លែងមួយទៀតនោះទេ។ ទោះយ៉ាងនេះក្តី អ្នកផ្តល់ព័ត៌មាននានាបានប្រាប់ពីក្តីបារម្ភថា ម្ចាស់ដី និងអ្នករស់នៅក្នុងមូលដ្ឋាន អាចត្រូវគេចាត់ទុកតាមផ្លូវច្បាប់ដោយច្រឡំថា ជាអ្នកមកតាំងលំនៅក្រៅផ្លូវការ ឬអ្នកមកទន្ទ្រានយកដី។ ហេតុនេះហើយ ពួកគាត់ខ្លាចអាជ្ញាធរធ្វើការឃាត់ខ្លួនពីបទកាន់កាប់ដីរដ្ឋ ឬដីសហគមន៍ដោយខុសច្បាប់ បណ្តេញគាត់ចេញពីដីធ្លីគាត់កាន់កាប់ដោយគ្មានផ្តល់សំណង ប្តឹងចោទប្រកាន់លើរូបគាត់ ឬដាក់ទោសគាត់ឲ្យជាប់ពន្ធនាគារ។

ទោះបីមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងដីធ្លី និងរក្សាទម្លាប់កសិកម្មបែបប្រពៃណីរបស់ខ្លួនក៏ដោយ ក៏មានការកំណត់ថា កសិកម្មពនេចរ ជាការគំរាមកំហែងចម្បងមួយដែលបង្កការរេចរឹលបាត់បង់ព្រៃឈើ និងដែលគម្រោងនេះព្យាយាមលុបបំបាត់ចោល។ អ្នកផ្តល់ព័ត៌មាននានា បានរាយការណ៍ថា លំហូរចូលជនចំណាកស្រុកដ៏ច្រើន បានបង្កការច្របូកច្របល់មិនដឹងថា តើប្រជាជនមូលដ្ឋាន (ប្រជាជនជនជាតិដើមភាគតិច) ឬអ្នកមកពីក្រៅ ដែលកំពុងធ្វើកសិកម្មពនេចរសព្វថ្ងៃ។ ហេតុនេះត្រូវធ្វើការពិនិត្យអង្កេតជាក់ស្តែងលើ សមាសភាពសហគមន៍មូលដ្ឋាន ដើម្បីធានាថា ការអនុវត្តគម្រោងមិនប៉ះពាល់ដល់សកម្មភាព កសិកម្មពនេចរតាមទម្លាប់របស់ប្រជាជនជនជាតិដើមភាគតិច។

គម្រោងនេះ ក៏បានអនុវត្តតាមគោលការណ៍ មានការយល់ព្រមជាមុន មានព័ត៌មានគ្រប់គ្រាន់ និងសេរីភាពក្នុងការចូលរួម (FPIC) ផងដែរ។ ការពិនិត្យអង្កេតដល់កន្លែងបានបង្ហាញជាទូទៅពី ចំណេះដឹងតិចលើខ្លឹមសារនៃកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ក្នុងចំណោមសហគមន៍នានា រួមទាំងបុគ្គលដែលយល់ព្រមលើការអនុវត្តគម្រោង រេដ+ ដោយបានផ្តិតមេដៃ ឬចុះហត្ថលេខា។ តួយ៉ាង នៅពេលមានការសាកសួរពីចំណុចសំខាន់ៗនៃ កិច្ចព្រមព្រៀង (ឧទាហរណ៍ សេចក្តីចែងពីការយល់ព្រម រយៈពេល យន្តការដោះស្រាយ-ជំទាស់តវ៉ា ក្នុងករណីភាគីណាមួយ មិនអនុវត្តតាមទំនួលខុសត្រូវរបស់ខ្លួន) តំណាងសហគមន៍ជនជាតិដើមភាគតិច មិនអាចផ្តល់ព័ត៌មានទាំងនេះបានឡើយ។ ការបកស្រាយសាមញ្ញមួយ គឺអាចមកពីពួកគាត់បានភ្លេចពីចំណុចសំខាន់ៗទាំងនោះ ឬក៏ក្រុមស្រាវជ្រាវលើកសំណួរមិនបានត្រឹមត្រូវ។ ទោះជាដូច្នេះក្តី លទ្ធផលសិក្សាបង្ហាញថា ត្រូវធ្វើការបន្ថែមទៀតលើដំណើរការ FPIC នេះ មុនពេលមានការស្នើសុំ និងការផ្តល់ការយល់ព្រម។

គម្រោងនេះ ព្យាយាមរក្សាប្រភេទផ្សេងៗនៃគម្របព្រៃឈើ និងបង្កើនចំនួនសត្វព្រៃដែលមានសារៈសំខាន់ សម្រាប់ការអភិរក្ស។ ក្នុងគោលដៅនេះ គម្រោងព្យាយាមកាត់បន្ថយការគំរាមកំហែងផ្នែកបរិស្ថាន ដូចជា ការបាត់បង់ជម្រកសត្វព្រៃ ការបរបាញ់តាមគ្រប់រូបភាព ការកាប់ឈើដោយជ្រើសរើស និងការប្រមូលផលនិងអនុផលព្រៃឈើច្រើនហួសប្រមាណ។ ឯកសារគម្រោងបង្ហាញថា គម្រោងព្យាយាមសម្រេចគោលដៅនេះ មួយចំណែកតាមរយៈប្រពលវប្បកម្មកសិកម្ម និងមួយចំណែកទៀតតាមការដាក់បញ្ចូលការប្រើប្រាស់ដោយមនុស្សនូវ ដីមិនមែនដីព្រៃស្ថិតក្នុងតំបន់គម្រោង ទៅក្នុងតំបន់គ្រប់គ្រងការជ្រាបចេញ។ តំបន់រងការជ្រាបចេញ រួមមាន ដីព្រៃទាំងឡាយដែលត្រូវបានកែប្រែទៅបម្រើការប្រើប្រាស់មិនមែនជាព្រៃឈើ ឬត្រូវបានកាប់ឆ្ការគិតត្រឹមឆ្នាំ២០១០ ក្នុងចម្ងាយមិនលើសពី ៣គីឡូម៉ែត្រពីកន្លែងតាំងលំនៅដ្ឋានរបស់អ្នកស្រុក។ គម្រោងនេះអនុវត្តសកម្មភាព

គ្រប់គ្រងការជ្រាបចេញមួយចំនួន ដូចជា អេកូទេសចរណ៍ និងការគ្រប់គ្រងអនុផលព្រៃឈើ នៅក្នុងកន្លែងមានព្រៃឈើនៃតំបន់គម្រោង និងតំបន់ទ្រនាប់មានការជ្រាបចេញ។ ទោះយ៉ាងនេះក្តី អ្នកផ្តល់សម្ភាសន៍បានប្រាប់ថា ការកាប់ឈើខុសច្បាប់ដែលអនុវត្តភាគច្រើនដោយអ្នកមកពីក្រៅ កំពុងបន្តទៅមុខក្នុងកម្រិតគួរឲ្យបារម្ភនៅក្នុងភូមិរបស់គាត់។ ហេតុនេះ អ្នកទ្រទ្រង់គម្រោងត្រូវធ្វើការពិនិត្យអង្កេត និងឆ្លើយតបទៅនឹងក្តីបារម្ភទាំងនេះ ព្រោះបរាជ័យក្នុងការបញ្ឈប់ការកាប់ឈើខុសច្បាប់នេះអាចបង្កគ្រោះថ្នាក់នៃការជ្រាបចេញសកម្មភាពនេះ ការប្រែប្រួលបញ្រ្ចាស និងភាពមិនអាចគង់វង្សជាអចិន្ត្រៃយ៍។

អ្នកទ្រទ្រង់គម្រោង បានជំរុញជាហូរហែនូវអ្នកពាក់ព័ន្ធជាច្រើន ជាពិសេសអ្នកនៅតាមតំបន់គម្រោង ឲ្យចូលរួមក្នុងដំណើរការពិគ្រោះយោបល់យ៉ាងធំទូលាយលើប្រធានបទផ្សេងៗទាក់ទងនឹងគម្រោង រេដ+ និងមិនទាក់ទងនឹងគម្រោង រេដ+។ ទោះយ៉ាងនេះក្តី សហគមន៍បានលើកបញ្ហាពីរឡើង ក្នុងពេលធ្វើការពិភាក្សាតាមក្រុមស្នូល។ ទី១ ពួកគេចង្អុលបង្ហាញថា ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធតទៅមុខទៀត គួរផ្តោតលើសកម្មភាព ឬឧបសគ្គក្នុងការអនុវត្តគម្រោងរេដ+។ តួយ៉ាង អ្នកផ្តល់ព័ត៌មានចង់ដឹងថា តើទម្លាប់ធ្វើកសិកម្មពនេចរនាពេលបច្ចុប្បន្នរបស់គាត់នឹងត្រូវហាមឃាត់ ឬយ៉ាងណា។ ទី២ ពួកគាត់ បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃ ការបង្កើនការចូលរួមចំណែករបស់ស្ត្រីនៅក្នុងដំណើរការពិគ្រោះយោបល់។

អ្នកទ្រទ្រង់គម្រោងបានណែនាំឲ្យប្រើនូវ យន្តការជំទាស់តវ៉ាមួយដែលអនុញ្ញាតឲ្យប្រជាជនមូលដ្ឋាន ដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅដល់ក្រុមអនុវត្តគម្រោង ដើម្បីធ្វើការវាយតម្លៃ និងដោះស្រាយ។ ក្រុមប្រឹក្សាឃុំក្នុងតំបន់គម្រោង ក៏មានភារកិច្ចតាមផ្លូវច្បាប់ ត្រូវទទួលយកបណ្តឹងរបស់អ្នកស្រុកលើបញ្ហាគ្រប់បែបយ៉ាង រួចហើយ ឬមួយបញ្ជូនបណ្តឹងទាំងនោះទៅកាន់ផ្នែកមានសមត្ថកិច្ចសមស្របតាមបណ្តឹង ឬមួយព្យាយាមដោះស្រាយវាដោយផ្ទាល់ ជាទូទៅតាមរយៈការសម្រុះសម្រួលរវាងភាគីរងការប៉ះពាល់។ ស្រដៀងគ្នានឹងសហគមន៍នៅឧត្តរមានជ័យដែរ នៅពេលសាកសួរពី បញ្ហាដែលពួកគេកំពុងប្រឈមមុខក្នុងការគ្រប់គ្រងព្រៃឈើនៅក្នុងភូមិខ្លួន សហគមន៍ជនជាតិដើមភាគតិចនៅសីមា បានពណ៌នាយ៉ាងក្បោះក្បាយពីរបៀបដែលអ្នកមកពីក្រៅស្រុក បានចូលមកកាប់ព្រៃឈើរបស់គាត់ដោយខុសច្បាប់។ អ្នកផ្តល់ព័ត៌មានម្នាក់បានប្រាប់ថា ទោះបីពួកគាត់បានដាក់បណ្តឹងតវ៉ាទៅអាជ្ញាធរទទួលខុសត្រូវខាងព្រៃឈើក៏ដោយ ក៏សកម្មភាពកាប់ឈើខុសច្បាប់ទាំងនេះ មិនទាន់មានការដោះស្រាយឲ្យបានសមស្របនៅឡើយ។ បញ្ហានេះ បានបង្កើតនូវមន្ទិលសង្ស័យជាច្រើនក្នុងចំណោមសហគមន៍នានា អំពីប្រសិទ្ធភាពនៃគម្រោងរេដ+ ក្នុងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ បង្កឡើងដោយអ្នកមកពីក្រៅស្រុក។ ប្រសិនបើការគំរាមកំហែងនេះ មិនអាចដោះស្រាយបានដោយសមស្របនោះទេ គម្រោងរេដ+ អាចជួបហានិភ័យនៃការជ្រាបចេញ ការមិនគង់វង្សជាអចិន្ត្រៃយ៍ និងការប្រែប្រួលបញ្រ្ចាសវិញ។

## សេចក្តីសន្និដ្ឋាន

UNFCCC (2013) បានកំណត់ឲ្យបណ្តាប្រទេសចូលរួមក្នុងគម្រោង រេដ+ រួមទាំងកម្ពុជាផង បង្កើតប្រព័ន្ធធានាសុវត្ថិភាពថ្នាក់ជាតិមួយ ដើម្បីផ្តល់តាមពេលវេលាទៀងទាត់មួយនូវ សង្ខេបព័ត៌មាន ស្តីពីរបៀបដោះស្រាយ និងគោរពតាមវិធានការការពារនានាក្នុងពេលអនុវត្តគម្រោង រេដ+។ ការវាយតម្លៃនេះបង្ហាញនូវបទពិសោធន៍ជាក់ស្តែងជាច្រើនដែលគួរដាក់បញ្ចូលទៅក្នុង ការរចនារៀបចំប្រព័ន្ធព័ត៌មានស្តីពី វិធានការធានាសុវត្ថិភាពថ្នាក់ជាតិដែលលេខាធិការដ្ឋាន រេដ+កម្ពុជា កំពុងបង្កើតឡើង (2015)។

ទី១ ជាការសំខាន់ត្រូវធានានូវសិទ្ធិកាន់កាប់ដីកសិកម្មមានស្រាប់ និងដីព្រៃ តាមទម្លាប់ពីមុនរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ព្រៃសហគមន៍ និងការចុះបញ្ជីដីធ្លី ជាមធ្យោបាយជាក់ស្តែង សម្រាប់ដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ ព្រោះពួកវាមិនសូវទាមទារពេលវេលា និងធនធានច្រើន។ អ្នកអនុវត្ត រេដ+ អាចត្រូវពិនិត្យពីកសិកម្មពនេចរ ដើម្បីកំណត់ថា តើវាធ្វើឲ្យខូចខាតប្រព័ន្ធអេកូឡូស៊ីមែន ឬយ៉ាងណា។ ប្រសិនបើដូច្នោះមែន ចាំបាច់ត្រូវស្វែងរក និងអនុវត្តសាកល្បងនូវជម្រើសផ្សេងទៀត ដើម្បីជំនួសកសិកម្មពនេចរ។

ទី២ ពិតមែនតែFPICជាឧបករណ៍សំខាន់មួយសម្រាប់ធានាថា អ្នកចូលរួមមានសេរីភាព និងព័ត៌មានគ្រប់គ្រាន់ក្នុងការយល់ព្រមចូលរួម នៅមុនពេលអនុវត្តសកម្មភាពគម្រោងនោះ ប៉ុន្តែអ្នកអនុវត្ត FPIC ត្រូវធានាដាច់ខាតថា ខ្លួនបានផ្តល់ព័ត៌មានពេញលេញ និងមិនមែនដោយជ្រើសរើសទៅឲ្យសហគមន៍ នៅមុនពេលស្នើសុំការយល់ព្រមចូលរួមពីពួកគេ។ មិនគួរសង្កត់ធ្ងន់ហួសពេកទេទៅលើឱកាសល្អដែលអាចកើតចេញពីគម្រោង រេដ+ ហើយក៏មិនគួរប្រាប់ដោយសម្រាលខ្លាំងពេកដែរពី ហានិភ័យអាចកើតមានឡើង។ ករណីនៅសីមាបង្ហាញថា ការយល់ដឹងជាទូទៅអំពីគម្រោង រេដ+ និងសកម្មភាពគម្រោង ហាក់នៅមានកម្រិតទាប។ ក្នុងករណីទាំងពីរនេះ អ្នកភូមិត្រូវការព័ត៌មានបន្ថែមអំពីទំហំនៃសកម្មភាព រេដ+ ជាពិសេសខ្លឹមសារនៃកិច្ចព្រមព្រៀងដែលពួកគេបានផ្តល់ការយល់ព្រម។ ការធ្វើដូច្នេះ គឺដើម្បីធានាថា អ្នកភូមិបានយល់ដឹងពេញលេញពីអត្ថប្រយោជន៍ និងហានិភ័យអាចកើតចេញពីគម្រោងរេដ+។ ជាការសំខាន់ដែរ ត្រូវគិតគូរពីកម្រិតនៃការយល់ដឹង និងបរិបទសង្គមរបស់អ្នកពាក់ព័ន្ធនានាដែលចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ដើម្បីធានាឲ្យមានការចូលរួមយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីសំណាក់ពួកគេ។

ទី៣ អ្នកទ្រទ្រង់គម្រោង រេដ+ ត្រូវធានាថា ភាគីពាក់ព័ន្ធទាំងអស់គោរពតាមយន្តការដោះស្រាយជំទាស់ ហើយតាមនេះបញ្ហានានាដែលកើតចេញពីការអនុវត្តគម្រោង ឬសកម្មភាពរបស់តួអង្គពីខាងក្រៅ គឺអាចដោះស្រាយបានដោយសមស្រប។ អប្រសិទ្ធភាពក្នុងការដោះស្រាយការជំទាស់តវ៉ា វាធ្វើឲ្យសហគមន៍នៅក្នុងគម្រោងសាកល្បងទាំងពីរ មានមន្ទិលសង្ស័យលើប្រសិទ្ធភាពនៃគម្រោងរេដ+។

ទី៤ គ្រោះថ្នាក់នៃការប្រែប្រួលបញ្រ្ចាស និងការកែប្រែដីព្រៃធម្មជាតិដោយសារសម្ពាធពីខាងក្រៅ រួមទាំង ការកាប់ឈើខុសច្បាប់ដោយតួអង្គនៅខាងក្នុង និងមកពីក្រៅតំបន់គម្រោង គឺនៅ

មាននៅឡើយ។ លទ្ធផលនៃការសិក្សានេះ មានផលពាក់ព័ន្ធចម្បងៗពីរ។ ទី១ ការសិក្សាផ្ដល់គំនិតថា អ្នកទ្រទ្រង់គម្រោងគួរវាយតម្លៃឡើងវិញពី កត្តាជំរុញការរេចរឹល និងបាត់បង់ព្រៃឈើដែលពួកគេកំពុងព្យាយាមដោះស្រាយ។ ទី២ ដើម្បីឲ្យគម្រោងរេដ+ ទទួលបានជោគជ័យ ត្រូវធានាថា បទបញ្ញត្តិ និងច្បាប់ទប់ស្កាត់ការកាប់ឈើខុសច្បាប់ ត្រូវបានពង្រឹងអនុវត្តន៍ជាបន្ទាន់។ កិច្ចការនេះទាមទារនូវ កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពពីសំណាក់វិស័យសំខាន់ៗដទៃទៀត ដូចជា វិស័យថាមពល កសិកម្ម និងពាណិជ្ជកម្ម ព្រមទាំងការបង្កើតចំណងតភ្ជាប់ជាមួយសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផ្អែកលើដីធ្លីផ្សេងៗទៀត។

## ឯកសារយោង


Angelsen, Arild. 2010. “Policies for Reduced Deforestation and their Impact on Agricultural Production.” *Proceedings of the National Academy of Sciences of the United States of America* 107(46): 19639-19644.

CCBS (Climate, Community and Biodiversity Alliance). 2016. “Reduced Emissions from Deforestation and Degradation in Seima Protection Forest.” www.climate-standards.org/ 2013/09/12/reduced-emissions-from-deforestation-and-degradation-in-seima-protection-forest-2/.

FA & WCS. 2011. *Overview of the Seima Protection Forest REDD Project*. Phnom Penh: Forestry Administration and Wildlife Conservation Society Cambodia Program.

Nguon Pheakkdey. 2014. *REDD+ Feasibility Assessment for Community Protected Areas in Cambodia*. Phnom Penh: Ministry of Environment, Adaptation Fund and United Nations Environment Programme.

Nguon Pheakkdey and Chhun Delux. 2015. *Background Document of Cambodia's National REDD+ Strategy*. Phnom Penh: REDD+ Taskforce Secretariat.

Nguon Pheakkdey and Dominik Kulakowski. 2013. “Natural Forest Disturbances and the Design of REDD+ Initiative.” *Environmental Science and Policy* 33(4): 332-345.

Peskett, Leo, and Kimberly Todd. 2013. “Putting REDD+ Safeguards and Safeguard Information Systems Into Practice.” UN-REDD Programme Policy Brief 03. Geneva: UN-REDD Programme Secretariat.

Roe, Stephanie, Charlotte Streck, Luke Pritchard and John Costenbader. 2013. *Safeguards in REDD+ and Forest Carbon Standards: A Review of Social, Environmental and Procedural Concepts and Application*. Washington, DC: Climate Focus.

RTS (REDD Taskforce Secretariat). 2015. *National REDD+ Strategy's Work Plan*. Phnom Penh: Cambodia REDD+ Tasforce Secretariat

UNFCCC (United Nations Framework Convention on Climate Change). 2013. *Report of the Conference of the Parties on its Nineteenth Session*. Warsaw, Poland: UNFCCC.

UNFCCC. 2014. “Glossary of Climate Change Acronyms.” http://unfccc.int/essential_background/glossary/items/3666.php#R.

UN-REDD Programme. 2015. “Journal 7: REDD+ Safeguards and Safeguard Information Systems.” *REDD+ Academy Learning Journal*.


*តពីទំព័រ ៥* **វិទ្យាល័យនៅកម្ពុជា...**

តទៅ៖ តើគួរអនុវត្តវិធានការគោលនយោបាយអ្វីខ្លះដើម្បីបង្កើនគុណភាពអប់រំថ្នាក់មធ្យមសិក្សា? និង តើកត្តាសង្គមអ្វីខ្លះដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស និងការអនុវត្តរបស់គ្រូនៅក្នុងថ្នាក់រៀន?

ទោះបីមានការប្រឹងប្រែងច្រើនហើយក្ដី ក៏កំណែទម្រង់កម្មវិធីសិក្សាមិនទាន់បានប្រណិតទេ ហើយភាពមិនស៊ីគ្នារវាងការសិក្សារបស់សិស្ស និងជំនាញដែលនិយោជកត្រូវការ នៅតែជាកង្វល់ដ៏ធំ។ ការអង្កេតបន្ថែម គួរផ្ដោតលើសំណួរស្រាវជ្រាវដូចតទៅ៖ តើមានជម្រើសគោលនយោបាយអ្វីខ្លះ សម្រាប់បន្តការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីឲ្យវានៅតែសមស្របតាមតម្រូវការ? តើកម្ពុជាអាចរក្សាតុល្យភាពបានល្អប៉ុណ្ណា រវាងការធ្វើស្តង់ដានីយកម្ម និងការកែសម្រួលតាមករណីនីមួយៗ (Customization) នៃការអភិវឌ្ឍកម្មវិធីសិក្សា? តើដំណើរការដាក់បញ្ចូល ការអប់រំនិងបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ ឈានដល់ដំណាក់កាលណាទៅហើយ? តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើការដាក់បញ្ចូល TVET ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ? តើការដាក់បញ្ចូលវិធីសាស្ត្របង្រៀនមានអន្តរកម្មច្រើន វាមានវិសាលភាពប៉ុណ្ណា? តើធ្វើយ៉ាងណាដើម្បីផ្សារភ្ជាប់ការបង្រៀនតាមបែបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ទៅនឹងវគ្គសិក្សាតាមប្រព័ន្ធអ៊ិនធឺណិត ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត? និង តើគ្រូបង្រៀនកម្ពុជា ត្រូវកសាងសមត្ថភាពឲ្យបានដល់កម្រិតណាដើម្បីអាចអនុវត្តវិធីសាស្ត្របង្រៀនមានអន្តរកម្មនេះបាន?

ដើម្បីអាចយល់កាន់តែច្បាស់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀននិងរៀនគួរ ការស្រាវជ្រាវទៅអនាគតគួរផ្ដោតលើសំណួរ ដូចជា៖ តើផលប៉ះពាល់ជាក់ស្ដែងនៃការបង្រៀនឯកជនទៅលើគុណភាពនៃការបង្រៀន កម្មវិធីសិក្សា លទ្ធផលសិក្សា និងសមភាពក្នុងការអប់រំ មានអ្វីខ្លះ? និង តើការបង្រៀនគួរនៅកម្ពុជានាពេលបច្ចុប្បន្ន មានស្ថានភាព និងនិន្នាការយ៉ាងដូចម្ដេច? ប្រធានបទស្រាវជ្រាវក្នុងផ្នែកនេះ រួមមាន ១) វិសមភាពនៃការអប់រំបង្កឡើងដោយការបង្រៀនឯកជន ២) ការយល់ឃើញរបស់សិស្ស ឪពុកម្ដាយ និងគ្រូបង្រៀន លើការបង្រៀនគួរ និង ៣) តម្លៃនៃការបង្រៀនគួរ។ ការស្រាវជ្រាវទៅអនាគតស្ដីពីការបង្រៀនឯកជន ក៏ត្រូវយកចិត្តទុកដាក់លើភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងវប្បធម៌ផ្សេងៗដែរ (Bray 2010)។

កម្មវិធីសុខភាពរបស់សាលា សំខាន់ខ្លាំងណាស់សម្រាប់ធានាឲ្យបាននូវជោគជ័យនៃការសិក្សា ក៏ដូចជា សុខភាពផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា និងសង្គមរបស់សិស្ស។ ការសិក្សាមួយចំនួនតូចដែលបានធ្វើឡើងកន្លងមក មានទំហំតូច ហើយផ្ដោតតែលើតំបន់ទីក្រុងប៉ុណ្ណោះ។ ដូច្នេះការស្រាវជ្រាវទៅអនាគតលើបញ្ហាសុខភាពក្នុងវិស័យអប់រំ គួរពង្រីកទៅដល់តំបន់ជនបទ ហើយការស្រាវជ្រាវដើម្បីធ្វើសកម្មភាព អាចនឹងផ្ដល់នូវករណីសិក្សាដ៏មានប្រយោជន៍ជាច្រើនបន្ថែមទៀត។

សរុបមក ការស្រាវជ្រាវ គួរធ្វើឡើងឲ្យបានទៀងទាត់ដើម្បីផ្ដល់ភស្តុតាង ដែលអាចរួមចំណែកដល់ការកសាងសមត្ថភាពធនធានមនុស្ស តាមរយៈកម្មវិធីសិក្សាដែលមានប្រសិទ្ធភាព គ្រូបង្រៀនដែលមានសមត្ថភាព និងកម្មវិធីអប់រំដែលសមស្របតាមតម្រូវការ។ ថវិកាជាតិ ក៏គួរមានចែកសម្រាប់ជួយទ្រទ្រង់ដល់ការសិក្សាស្រាវជ្រាវផ្នែកអប់រំ ជាពិសេស ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិដែរ។

**ឯកសារយោងមាននៅក្នុងអត្ថបទជាភាសាអង់គ្លេស**